## មជ្ឈមណ្ឌលឯកសារកម្ពុជា

### សម្ភាសន៍ជាមួយឈ្មោះ ថូ លន ភេទប្រុស អាយុ៥៨ឆ្នាំ

### មុខងារជំនាន់ខ្មែរក្រហមៈ “និរសារ”

### សព្វថ្ងៃនៅភូមិអូរគគីរកណ្តាល ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

### ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២

### សម្ភាសន៍ដោយៈ វ៉ាន់ថាន់ ពៅដារ៉ា

### ០០:២១:២៧

### ០១:៥៨:២៥

### ២៣ទំព័រ

ដារ៉ា : ដំបូងពូឈ្មោះអី?

លន់ : ឈ្មោះ ថូ លន ។

ដារ៉ា : អាយុប៉ុន្មានហើយ?

លន់ : ៥៨ឆ្នាំ ។

ដារ៉ា : ពូមានស្រុកកំណើតនៅណា?

លន់ : នៅភូមិជួយចក្រី ឃុំស្រីញ៉័រ ស្រុកពួក ខេត្តសៀមរាប ។

ដារ៉ា : សព្វថ្ងៃពូរស់នៅភូមិ ឃុំអី?

លន់ : ភូមិអូរគគីរកណ្តាល ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

ដារ៉ា : គ្រួសារពូឈ្មោះអីដែរ?

លន់ : ផេង ខឿន ។

ដារ៉ា : អាយុប៉ុន្មានហើយ?

លន់ : ៤៩ឆ្នាំហើយ ។

ដារ៉ា : គាត់អ្នកស្រុកណា?

លន់ : ភូមិពងទឹក ឃុំពងទឹក ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ។

ដារ៉ា : ពូមានកូនចៅប៉ុន្មាននាក់?

លន់ : មាន ៦នាក់ ស្រី ៣ ប្រុស ៣ ។

ដារ៉ា : ពូមានបងប្អូនប៉ុន្មាននាក់?

លន់ : មាន៧នាក់ ។

ដារ៉ា ៖ ប្រុសប៉ុន្មាន? ស្រីប៉ុន្មាន?

លន់ ៖ ប្រុស៣ ស្រី៤ ។

ដារ៉ា ៖ ពូជាកូនទីប៉ុន្មាន?

លន់ ៖ កូនច្បង ។

ដារ៉ា ៖ ឪពុកពូឈ្មោះអី?

លន់ ៖ ឈ្មោះថូ ណុក ស្លាប់ហើយកាលឆ្នាំ៧៩ ។

ដារ៉ា ៖ ចុះម្ដាយ?

លន់ ៖ ឈ្មោះតាត ទន់ នៅរស់សព្វថ្ងៃនេះ ។

ដារ៉ា ៖ ពូមានមុខងារអីដែរសព្វថ្ងៃនេះ?

លន់ ៖ ខ្ញុំជាមេភមិអូរគគីរកណ្ដាល ។

ដារ៉ា ៖ បើពូជាអ្នកសរសេរសៀវភៅប្រវត្តិសាស្ត្រស្រុកអន្លង់វែងហ្នឹង តើពូចង់សរសេរពីអីខ្លះ?

លន់ ៖ ពីភាពជូរចត់ជាច្រើនកាលពីមុន ដែលខ្ញុំចេញពីស្រុកមកនៅនេះប្រហែលជាឆ្នាំ៧៣ ។

ដារ៉ា ៖ ពូចេញពីស្រុកកំណើតឆ្នាំ៧៣?

លន់ ៖ បាទ! តែធ្លាប់ជូនពួកគេមក ។

ដារ៉ា ៖ អញ្ចឹងឆ្នាំ៧៣ហ្នឹងពូចូលបម្រើបដិវត្តន៍?

លន់ ៖ បាទ! តែកាលហ្នឹងខ្ញុំក៏នៅក្មេងដែរ ។

ដារ៉ា ៖ មុនពេលពូចូលបម្រើហ្នឹងពូមានបានរៀនសូត្រអីទេ?

លន់ ៖ មិនបានរៀនទេ ។

ដារ៉ា ៖ ពេលចូលធ្វើបដិវត្តន៍ហ្នឹងពូធ្វើជាអី?

លន់ ៖ កាលហ្នឹងខ្ញុំរស់នៅជាកុមារ កាលហ្នឹងគេហៅរត់និរសារឲ្យគេ ។

ដារ៉ា ៖ រត់និរសារឲ្យអ្នកណាគេ?

លន់ ៖ រត់ឲ្យអង្គភាពទ័ព ។

ដារ៉ា ៖ ទ័ពស្រុក ឬក៏តំបន់?

លន់ ៖ ទ័ពតំបន់ ។

ដារ៉ា ៖ តំបន់អីគេ?

លន់ ៖ តំបន់ឲ្យ១៨៤ ហៅថាភូមិភាគឧត្ដរ ។

ដារ៉ា ៖ កាលហ្នឹងពូមានគ្នាប៉ុន្មាននាក់?

លន់ ៖ ៦នាក់ ។

ដារ៉ា ៖ អាយុប៉ុន្មា?

លន់ ៖ មានបងមានប្អូនដែរ ។

ដារ៉ា ៖ នៅតំបន់១៨៤ហ្នឹងអ្នកណាជាលេខា ជាមេទ័ព?

លន ៖ តាប៉ែនធំជាងគេ បន្ទាប់មោតាសុត ហើយតាសៀន អាហ្នឹងខាងកងទ័ពជំនាន់ហ្នឹង ។

ដារ៉ា ៖ កាលហ្នឹងពូនៅជាមួយអ្នកណា?

លន់ ៖ នៅជាមួយ តា ហេង ហ្នឹងស្លាប់ហើយ ។

ដារ៉ា ៖ កាលហ្នឹងគាត់មានតួនាទីអី?

លន់ ៖ ជាប្រធានអនុសេនាធំ ហៅថាកងធំ ។

ដារ៉ា ៖ រត់និរសារហ្នឹងទៅខាងណាខ្លះ?

លន់ ៖ ពីភូមិខ្ញុំមោទាក់ស្មែងហើយពីទាក់ស្មែងហ្នឹងមោស្រែណយ ដល់ឆ្នាំ១៩៧៧ ហ្នឹងពួកប៉ែន ពួកសុត ពួកសៀន ហ្នឹងត្រូវបានគេសម្លាប់ទាំងអស់បានគេឲ្យខ្ញុំមកនៅឧត្ដរមានជ័យ ។

ដារ៉ា ៖ ពេលពូរត់និរសារហ្នឹងទៅទាក់ស្មែងហ្នឹងគេមានកងអីគេប្រចាំការនៅហ្នឹងអត់?

លន់ ៖ មានមូលដ្ឋាននៅទាក់ស្មែង និងស្រែណយ ។

ដារ៉ា ៖ អញ្ចឹងនៅជិតអន្លង់វែងដែរ?

លន់ ៖ ហើយមានពេលខ្លះពួកគេហ្នឹងមករៀននៅអន្លង់វែងហ្នឹង ។

ដារ៉ា ៖ កាលហ្នឹងនៅអន្លង់វែងហ្នឹងមានប្រជាជនដែរ?

លន់ ៖ មានា គេទើបតែជម្លៀសចេញពីឆ្នាំ៧៥-៧៦ហ្នឹង ។

ដារ៉ា ៖ ពូធ្វើជានិរសារពីឆ្នាំ៧៣មោ?

លន់ ៖ ពី៧៣-៧៩ ។

ដារ៉ា ៖ ពីឆ្នាំ៧៣-៧៥ហ្នឹងពូរត់ទៅណាខ្លះ?

លន់ ៖ ៧៣-៧៥ហ្នឹងជាពេលរំដោះកាលហ្នឹងខ្ញុំនៅភូមិ ដល់ឆ្នាំ៧៧ បានខ្ញុំចេញទៅទៀត ព្រោះថាខ្ញុំនៅភូមិហ្នឹងពួកមេៗខ្ញុំហ្នឹងថាខ្ញុំក្បត់ច្រើន ហើយខ្ញុំប្រមូលពួកខ្ញុំដែលជាប់គុកហ្នឹងរត់មកនៅឧត្ដរមានជ័យ ។

ដារ៉ា ៖ អញ្ចឹងពូនៅភូមិហ្នឹងយ៉ាងម៉េច?

លន់ ៖ នៅជាសហករណ៍ក្នុងកងកុមារ ។

ដារ៉ា ៖ ការរត់ហ្នឹងភឺតភ័យ?

លន់ ៖ ទី១ ភឺតភ័យ និងទី ២ មេខ្លះនៅឧត្ដរមានជ័យ ព្រោះថាពេលរំដោះមេរត់មកឧត្ដរមានជ័យអស់អញ្ចឹងហើយរត់មកតាមមេមកនៅឧត្ដរមានជ័យអស់ ។

ដាវ៉ី ៖ មេណាខ្លះរត់មកនៅខត្តរមានជ័យ?

លន់ ៖ តា ហេង គេឲ្យមកខត្តរមានជ័យក្រោយពេលរំដោះ ។

ដាវ៉ី ៖ មកនៅណា?

លន់ ៖ នៅក្នុងភូមិឈូក ហើយមកដល់ហ្នឹងខ្ញុំដាច់ពីតាហេង ទៀតឲ្យខ្ញុំមកនៅខាងស្រុក ព្រោះតាហេង ហ្នឹងគាត់នៅខាងកងទ័ពតំបន់ ។

ដាវ៉ី ៖ កាលហ្នឹងគាត់មានឋានៈអី?

លន់ ៖ កងវរសេនាតូច ។

ដាវ៉ី ៖ ស្ថិតនៅក្នុងកងពលណា?

លន់ ៖ គេហៅថា ពួកទ័ពខត្តរ ។

ដាវ៉ី ៖ អញ្ចឹងពូមកនៅជាមួយអ្នកណា?

លន់ ៖ មកនៅជាមួយគណៈស្រុក ។

ដាវ៉ី ៖ គណៈស្រុកអី?

លន់ ៖ ស្រុកសំរោង ឈ្មោះ សារិក ហើយខ្ញុំនៅបាន០៥-០៦ខែ ដល់ឆ្នាំ៧៨ ក៏គេចាប់តាសារិកហ្នឹងទៅទៀតគេថាក្បត់!

ដាវ៉ី ៖ នៅក្រោម តា សារិក ហ្នឹងមានអ្នកណាទៀត?

លន់ ៖ ខ្ញុំមិនសូវចាំទេ ។

ដាវ៉ី ៖ និរសារកាលហ្នឹងធ្វើការងារអីខ្លះ?

លន់ ៖ រត់សំបុត្រឲ្យគេទៅស្រុកសំរោងផង និងទៅស្រុកបន្ទាយអំពិល និងមោអន្លង់វែងនេះដែរ អាហ្នឹងនៅឆ្នាំ៧៧-៧៨ ។

ដាវ៉ី ៖ អ្នកណាគណៈស្រុកបន្ទាយអំពិល?

លន់ ៖ កាលហ្នឹងគណៈស្រុកមិនទាន់មានទេ មានតែឃុំ ។

ដាវ៉ី ៖ ឃុំអីគេ?

លន់ ៖ នៅឃុំបេង ។

ដាវ៉ី ៖ អ្នកណាមេឃុំបេង?

លន់ ៖ តា វ៉ាង ទៅខាងឃុំស៊ីលៀន ឈ្មោះតា គុន តា ផែន ហើយមោខាងកូនគ្រៀល ឈ្មោះតា នាង ។

ដាវ៉ី ៖ ចុះខាងអន្លង់វែងនេះ?

លន់ ៖ គណៈស្រុកឈ្មោះ ដោត ។

ដាភ៌ ៖ តា ដុះហ្នឹងអ្នកស្រុកណា?

លន់ ៖ មិនដឹងទេ បើពួក តា សារិក តា ផែន តាគុន តា នាង នោះដឹងតែមោខាងនិរតីហ្នុង ។

ដាភ៌ ៖ ចុះអនុតាដុះ?

លន់ ៖ មិនដឹងទេ ឲ្យសំបុត្រគេហើយជិះសេះទៅវិញ ។

ដាភ៌ ៖ កាលហ្នឹងជិះសេះសុទ្ធហ្នុង?

លន់ ៖ ជិះ០៣យប់បានមកដល់ ។

ដាភ៌ ៖ ជិះហ្នឹងមានចូលឃុំអីដែរ?

លន់ ៖ ចូលកន្លែងសហករណ៍ដើម្បីរកបាយហូប ចូលពីភូមិមួយទៅភូមិមួយ បើមិនមានភូមិទេយើងចូលកន្លែងកងទ័ព ។

ដាភ៌ ៖ មកម្តងៗមានគ្នាប៉ុន្មាននាក់?

លន់ ៖ ៥-៦នាក់ បើមោគ្នាតិចមិនហ៊ានមក ព្រោះកាលហ្នឹងសុទ្ធតែខ្លាដំរី ។

ដាភ៌ ៖ មកតាមផ្លូវហ្នឹងមានជបប្រទះប្រជាជននៅសហករណ៍ទេ?

លន់ ៖ ជួបតាមសហករណ៍ដូចជា នៅកាដែងហើយបានបន្តមករំចេក កាលនោះនៅមូលដ្ឋានអន្លង់វែងនេះធំ យើងនៅរំចេកនោះទេ មិនមែននៅអន្លង់វែងទេ ។

ដាភ៌ ៖ ទីតាំងនៅអន្លង់វែង?

លន់ ៖ ទីតាំងនៅអន្លង់វែង កន្លែងសំខាន់នៅរំចេក ។

ដាភ៌ ៖ ពូមោពីសំរោងចូលភូមិណាខ្លះ?

លន់ ៖ អូរឬស្សី ហើយបានមោភូមិបាក់នឹម មោអាគោ រួចបានព្រៃផ្តៅ ហើយបានមោតាដេវលំទងមោ ហើយបានមកដល់រំចេកហ្នុង ។

ដាភ៌ ៖ អូរឬស្សីហ្នឹងជាភូមិ ឬជាឃុំ?

លន់ ៖ ជាភូមិនៅក្នុងស្រុកសំរោងហ្នឹង!

ដាភ៌ ៖ ចុះបាក់នឹម?

លន់ ៖ ភូមិដូចគ្នា ។

ដាភ៌ ៖ អាគោ?

លន់ ៖ អង្គភាពកងទ័ព ។

ដាភ៌ ៖ ទ័ពអី?

លន់ ៖ ទ័ពតំបន់ ។

ដាភ៌ ៖ តំបន់ប៉ុន្មាន?

លន់ ៖ គេហៅតំបន់ខុគ្គរ ។

ដារ៉ា ៖ ចុះព្រៃផ្ដៅ?

លន់ ៖ ភូមិ ។

ដារ៉ា ៖ តាដេវ?

លន់ ៖ ភូមិ ។

ដារ៉ា ៖ លំទង?

លន់ ៖ ភូមិ ។

ដារ៉ា ៖ រំចេក?

លន់ ៖ ភូមិ ។

ដារ៉ា ៖ តែស្នាក់ការស្រុកនៅហ្នឹង?

លន់ ៖ ស្រុកផង ទាហានផងនៅដាច់ពីគ្នា ។

ដារ៉ា ៖ ពេលពូរត់សំបុត្រមោហ្នឹងពីរដង អញ្ចឹងពូមានឃើញប្រជាជនមានសភាពម៉េចដែរ?

លន់ ៖ ពេលព្រឹកឡើងឃើញគេចេញអស់ទៅ ហើយល្ងាចឡើងឃើញគេមោជុំគ្នាវិញមោ ។

ដារ៉ា ៖ ពេលរត់សំបុត្រហ្នឹងគណៈស្រុកសំរោងគេណែនាំម៉េចទៅ?

លន់ ៖ ត្រូវរក្សាការណ៍សម្ងាត់ និងការពារសំបុត្រឲ្យបាន ហាមដាច់មិនឲ្យបើកសំបុត្រមើល ។

ដារ៉ា ៖ ពេលពូនាំសំបុត្រមកហ្នឹង សំបុត្រហ្នឹងមានកម្រាសណា?

លន់ ៖ ដូចតែសំបុត្រធម្មតា!

ដារ៉ា ៖ ពេលពូយកសំបុត្រហ្នឹងទៅដល់ ពូយកឲ្យអ្នកណា?

លន់ ៖ យកទៅឲ្យតាមការណែនាំរបស់គេទៅ ដល់យកឲ្យយើងរង់ចាំការឆ្លើយតបរបស់គេ ។

ដារ៉ា ៖ ចាំយូរទេ?

លន់ ៖ មិនយូរទេ ។

ដារ៉ា ៖ មុនតាដុះ ហ់ងអ្នកណាគណៈស្រុកអន្លង់វែង?

លន់ ៖ មិនដឹងទេ ព្រោះថាការចាប់ហ្នឹងអ្នកស្រុកត្រូវជម្លៀសចេញពីអន្លង់វែងទាំងអស់ ។

ដារ៉ា ៖ នៅឆ្នាំណា?

លន់ ៖ ចុងឆ្នាំ៧៧ ។

ដារ៉ា ៖ ចុងឆ្នាំ៧៧ ពេលគេចាប់ តា សារិក ហ្នឹង?

លន់ ៖ បាទ ។

ដារ៉ា ៖ នៅអន្លង់វែងនេះចាប់ដែរ?

លន់ ៖ ចាប់តា ដុះ ដែរព្រោះថាបាត់ ។

ដារ៉ា ៖ ចាប់ហ្នឹងពូដឹងទេ?

លន់ ៖ ដាច់អស់ហើយបើគេចាប់មេអស់ហើយ អញ្ចឹងយើងនៅតាមអគ្គភាពរៀងៗខ្លួនចាំមេថ្មីគេមកទៀត ។

ដារ៉ា ៖ អ្នកស្រុកអន្លង់វែង ត្រូវជម្លៀសចេញទៅណា?

លន់ ៖ មួយចំនួនទៅខាងវ៉ារិន មួយចំនួនទៅខាងព្រៃស្នំ ហើយមួយចំនួនទៅខាងក្រឡាញ់ ហើយមួយចំនួនទៀតទៅដល់ចំការ ។

ដារ៉ា ៖ អញ្ចឹងនៅគណៈស្រុករំចេកមិនមានមនុស្សនៅទេអី?

លន់ ៖ មិនមានទេទៅជាកន្លែងមូលដ្ឋានកងទ័ពទាំងអស់ ។

ដារ៉ា ៖ កងទ័ពខត្តរ?

លន់ ៖ កងទ័ពភូមិភាគខត្តរ ដល់ទៅខាងបន្ទាយឆ្មាខាងលិចបាត់ដំបងនោះ គេហៅថាពួកពាយព្យ ហើយបើទៅខាងព្រះវិហារនោះវិញគេហៅថាពួកខត្តរដូចគ្នាតែគេហៅពួក១០៣វិញ ។

ដារ៉ា ៖ អ្នកណាជំនួសតាសារិក?

លន់ ៖ ឈ្មោះតាសារុំ មកពីនិរតីដូចគ្នា ។

ដារ៉ា ៖ គាត់មកតែឯង?

លន់ ៖ គាត់មករៀបចំរដ្ឋអំណាចនៅសំរោងហ្នឹង ។

ដារ៉ា ៖ ចុះវ៉ាង ឃុំបេងហ្នឹងបាត់ទេ?

លន់ ៖ មិនបាត់ទេ! ពីកំពង់ចាម ពីក្រចេះ ពីកំពង់ធំ ដែលធ្លាប់ធ្វើជាមេៗត្រូវដកចេញ ស្លូរហើយទី០១គេចាប់ ហើយទី០២ទៅកន្លែងកសាង ហើយមួយចំនួនក៏នៅរស់នៅក្រឡាញ់ ហើយមួយក៏បាត់ទៅ ។

ដារ៉ា ៖ ពេលពូនៅរត់សំបុត្រហ្នឹង ពូមានធ្លាប់រត់ទៅកន្លែងផ្សេងៗទៀតទេ?

លន់ ៖ ទៅតាមទិសដៅរបស់គេ ហើយស្រុកគេប្រើតែនិរសារស្រុករបស់គេទេ ហើយពួកខ្ញុំមាន៣ក្រុម ។

ដារ៉ា ៖ អញ្ចឹងពូមិនដែលរត់សំបុត្រទៅឃុំទេ?

លន់ ៖ ទៅ! ឃុំបេង ឃុំស៊ីលៀន នៅស្រុកបន្ទាយអំពិល ហើយស្រុកសំរោងនេះ ខ្ញុំរត់តែឃុំកូនគ្រៀលមួយទេ ។

ដារ៉ា ៖ គណៈស្រុកបន្ទាយអំពិល?

លន់ ៖ មិនមានទេ មានតែមេឃុំគេហៅមកប្រជុំនៅគណៈសំរោង ។

ដារ៉ា ៖ ក្រោយពីការផ្សារនិរសារធ្វើអីទៀត?

លន់ ៖ គេឲ្យដាំដំណាំឲ្យគេហូប ហើយក្នុងក្រុមខ្ញុំមានគ្នា៥នាក់សម្រាប់មនុស្ស៣០០នាក់ក្នុងអង្គភាពខ្ញុំ ។

ដារ៉ា ៖ អង្គភាពស្រុក?

លន់ ៖ បាទ! វាមានប្រុសស្រី ហើយស្រីនោះគេហៅថាកងចល័ត ហើយពួកប្រុសដែលជាប់នឹងនិន្នាការនយោបាយតាសារិក ហ្នឹងគេយកមកនៅនេះទាំងអស់ ហើយខ្ញុំដាំដំណាំពី៧៧-៧៩ ។

ដារ៉ា ៖ អញ្ចឹងទំហំដាំហ្នឹងប៉ុន្មាន?

លន់ ៖ ប្រហែលជា០៥ហិចតា ។

ដារ៉ា ៖ អញ្ចឹងដាំតែ០៥នាក់ហ្នឹង?

លន់ ៖ ០៥នាកតែមានជំនួយពីកងចល័ត ។

ដារ៉ា ៖ គ្រប់គ្រាន់ ទេ?

លន់ ៖ ដាំរហូតដល់មានផ្ទះដាក់ ហើយការហូបចុកមានការខ្វះដែរ ព្រោះគេឲ្យហូបបបរលាយពោតលាយដំឡូង ។

ដារ៉ា ៖ អញ្ចឹងឈ្មោះរុំ នេះនៅដល់៧៩?

លន់ ៖ បាទ! នៅដល់៧៩ហ្នឹងវៀតណាមចូលមកក៏រត់ទាំងអស់គ្នាទៅ ពួកទ័ព និងពួកស្រុកក៏រត់ចេញ ពីសំរោងទៅស្រុកបន្ទាយអំពិល រួមគ្នាទាំងអស់នៅស្រុកអំពិលកំណត់បង្កើត ទៅជាកងទ័ពខ្មែរ ទាំងអស់មិនមានស្រុកមិនមានតំបន់អីទេ ។

ដារ៉ា ៖ ពេលរត់ចេញទៅប្រហែលមានកម្លាំងប៉ុន្មាននាក់?

លន់ ៖ បើនិយាយទៅប្រហែលជារាប់ម៉ឺននាក់!

ដារ៉ា ៖ ចុះកម្លាំងប៉ុណ្ណឹងទប់ទល់ជាមួយវៀតណាមមិនបានទេអី?

លន់ ៖ មិនអាចទប់ទល់បានទេ ព្រោះរត់ចេញពីនេះទៅដល់នោះគេបំបែកចេញជាអង្គភាពមកវិញ ហើយធ្វើទៅតាមមុខសញ្ញារបស់គេ ហើយអ្នកខ្លះនេះជួនកាលមកធ្វើការនៅចុងកាល ហើយខ្លះទៀតមកអន្លង់វែងនេះទៅ ហើយអ្នកខ្លះទៀតនៅបន្ទាយអំពិលទៅ ហើយអ្នកខ្លះនៅសំរោងទៅ!

ដារ៉ា ៖ ក្រោយពេលវៀតណាមចូលបានប៉ុន្មានខែបានបែងចែក?

លន់ ៖ ខែ០១ ខែ០២ បានបែងចែកកម្លាំង!

ដារ៉ា ៖ អ្នកណាទទួលរួមក្នុងទ័ពខ្មែរហ្នឹង?

លន់ ៖ តាទេន ហើយឥឡូវគាត់ស្លាប់ហើយ មិនយូរប៉ុន្មានបានតាសឿន មកលើតាទេន ហ្នឹងទៀត!

ដារ៉ា ៖ អាចថាបង្កើតជាកងពលអីទេ?

លន់ ៖ កងពលទាំងអស់ហើយតែមិនដឹងជាមានឈ្មោះយ៉ាងទេ ទេឈ្មោះកងវរៈមាន ដល់ឈ្មោះកងពលគេឲ្យឈ្មោះជាខត្តុរ ឬលេខ១៨៤!

ដារ៉ា ៖ មានប៉ុន្មានវរសេនាធំ?

លន់ ៖ មិនដឹងទេ!

ដារ៉ា ៖ ពូនៅវរណា?

លន់ ៖ វរសេនាតូច៤៣ ហើយក្រោយមោគេឲ្យខ្ញុំទៅនៅកងតាសឿន ហើយក្រោយមកទៀតក៏ គេឲ្យខ្ញុំមកនៅនេះទៅ នៅឆ្នាំ៧៩ ខែ១០៩!

ដារ៉ា ៖ ពេលពូនៅវរសេនាតូច៤៣?

លន់ ៖ នៅ៤៣ហ្នឹង ប៉ុនគេដកខ្ញុំទៅនៅកងពិសេសវិញ !

ដារ៉ា ៖ អ្នកណាជាប្រធានវរសេនាតូច៤៣?

លន់ ៖ តាប៉ន ហើយដកពីកងពិសេសហ្នឹងឲ្យមកនៅនេះ!

ដារ៉ា ៖ នៅកងពិសេសហ្នឹងអ្នកណាដឹកនាំ?

លន់ ៖ តារ៉ាត ហ្នឹងអគ្គភាពផ្សេងទេ តាអ៊ីន តារ៉ែត តាឆយ នៅរស់សព្វថ្ងៃហ្នឹងនៅក្បែរហ្នឹងដែរ ហើយតាលម មេក្រុមខ្ញុំហើយសព្វថ្ងៃរស់នៅ១០៥!

ដារ៉ា ៖ អញ្ចឹងកងពលពិសេសនេះនៅក្រោមតាសឿន?

លន់ ៖ ហ្នឹងហើយ!

ដារ៉ា ៖ ហើយខែ១០៩ ៧៩ហ្នឹងមកនៅលំទងហ្នឹងនៅ?

លន់ ៖ បាទ! នៅតែកងពិសេសហ្នឹងដដែល ហើយខែ១០-១១ គេឲ្យខ្ញុំនៅច្រក៨០៨ ដើម្បីបើកច្រកទទួលសម្ភាររបស់របរម្ហូបអាហារ!

ដារ៉ា ៖ កងពិសេសពូមកទាំងកង?

លន់ ៖ បាទ! នៅកន្លែងនៅលើភ្នំ!

ដារ៉ា ៖ ៨០៨ហ្នឹងជាឈ្មោះកន្លែង?

លន់ ៖ ជាច្រកដើម្បីឲ្យថៃដឹកជញ្ជូនមួយរយៈហ្នឹងពីថៃមកខ្មែរគេហៅ៨០៨ ហើយនេះគេហៅ៨០៨ ហើយទៅខាងកើតនោះគេហៅ១០០៣ ហើយទៅខាងនោះគេហៅ១០០២ ហើយទៅខាងនោះគេហៅ១០០១ ជាច្រកដើម្បីបើសម្រាប់ផ្គត់ផ្គង់!

ដារ៉ា ៖ បើនិយាយទៅច្រកនេះបើកសម្រាប់ផ្គត់ផ្គង់ប៉ុន្មានកងពល?

លន់ ៖ ព្រោះថានៅនេះកម្លាំងកងទ័ពនៅខាងកំពង់ធំក៏គេហៅមកបើកយករបស់របរនៅនេះដែរ ហើយបើគេហៅទៅ១០០៣ ក៏ទៅហើយបើគេហៅទៅ១០០២ក៏ទៅ!

ដារ៉ា ៖ អ្នកណាគ្រប់គ្រងរួមនៅច្រក៨០៨ហ្នឹង?

លន់ ៖ តាសឿន ហើយគេដកខ្ញុំមកនៅក្នុងឃ្លាំងដាក់សមាររបស់របរអីម្តងដើម្បីផ្គត់ផ្គង់កងទ័ព!

ដារ៉ា ៖ នៅឆ្នាំណា?

លន់ ៖ ឆ្នាំ៨០ហើយ!

ដារ៉ា ៖ ឃ្លាំងហ្នឹងដាក់អីខ្លះ?

លន់ ៖ សម្រាប់ដាក់អង្ករ កាំភ្លើង គ្រាប់ ខោអាវ!

ដារ៉ា ៖ អាហ្នឹងមានទីតាំងនៅណា?

លន់ ៖ នៅ៨០៨លើភ្នំ!

ដារ៉ា ៖ អាហ្នឹងគេហៅថាឃ្លាំង៨០៨?

លន់ ៖ ឃ្លាំង៨០៨ ច្រក៨០៨!

ដារ៉ា ៖ សព្វថ្ងៃហ្នឹងនៅកន្លែងណា?

លន់ ៖ សព្វថ្ងៃនេះគេហៅ៨០៨ដូចគ្នា ហើយច្រកចំពីក្រោមនេះទៅគេហៅថា ផ្កាមរមាស សម័យយើងអាណានិគម មួយឃុំមួយគេហៅថាឃុំផ្កាមរមាស!

ដារ៉ា ៖ តាសឿន ហ្នឹងគ្រប់គ្រង់ឃ្លាំងរួមនៅ៨០៨ហ្នឹង?

លន់ ៖ បាទ! ហើយថ្ងៃ១០ ខែ០៥ ឆ្នាំ៨០ មានព្រឹត្តិការណ៍បាញ់តាសឿន!

ដារា ៖ ខាងណាបាញ់?

លន់ ៖ រវាងពួកខត្តរ និងពួកនិរតី!

ដារ៉ា ៖ តាសឿន នៅខាងណា?

លន់ ៖ តាសឿន ជាមេនៅខាងក្នុងអង្គភាពហើយមានបញ្ហាជាច្រើនដែលសម្លាប់គាត់ កូនទាហាននៅក្នុងអង្គភាពហ្នឹងរួមគ្នាសងសឹក!

ដារ៉ា ៖ កងទ័ពខត្តរហ្នឹងអីជាអ្នកបាញ់តាសឿន?

លន់ ៖ ហ្នឹងហើយ!

ដារ៉ា ៖ ទាក់ទងនឹងអីបានបាញ់តាសឿនហ្នឹង?

លន់ ៖ ទាក់ទងនឹងរបប០៣ឆ្នាំហ្នឹងគាត់ទៅនៅខត្តរមួយរយៈហ្នឹងមានការក្បត់ទៅមកៗ ហ្នឹងអញ្ចឹងហើយគេគុំរហូតពីហ្នឹងមក ហើយដល់វៀតណាមចូលមកក៏គេនៅតែគុំ ដោយសារគាត់បានសម្លាប់មិត្តភក្តិគេដែលគេរួមអាវុធយូរមកហើយនោះ អញ្ចឹងហើយបង្កើតបានជាសងសឹក!

ដារ៉ា : អញ្ចឹងហើយមានការសម្លាប់គ្នាទៀត?

លន់ : គេហៅថា ការលួចសម្លាប់ ទាំងតាម៉ុក ប្រកាសថាទោះបីដាដាច់ដៃដាច់ជើងយ៉ាងហោចណាស់ក៏បង្កើតកូនបានដែរមិនត្រូវឲ្យមានសម្លាប់ទេ ហើយមុនហ្នឹងសម្លាប់ក៏ឲ្យមានការវិនិច្ឆ័យឲ្យបានត្រឹមត្រូវ តែតាសឿនបំពាន!

ដារ៉ា : អញ្ចឹងតាសឿន នៅណាពេលបាញ់សម្លាប់ហ្នឹង?

លន់ : នៅ៨០៨ នៅទីចាត់ការក្នុងកងពលខត្តរ!

ដារ៉ា : កាលហ្នឹងពូចូលរួមនឹងគេដែរ?

លន់ : ខ្ញុំមិនដឹងផង ខ្ញុំរត់យករួចខ្លួនហើយ ហើយអ្នកសម្លាប់ហ្នឹងវាសម្លាប់តែពួកនិរតី ហើយដល់ក្រោយមោមិនឲ្យមានការកាប់សម្លាប់ទៀត ហើយខាងនេះគេដូល់ដាមតិថា បេ់តាសឿននៅមិនបានទេ តាសឿនចេញមកហើយ បានគេចាប់ផ្ដើមឲ្យតាសឿនទៅ១០០១ ដល់១០០២ បានតាសឿនឈប់នៅហ្នឹងគាត់រត់ទៅបារ៉ៃ ហើយខ្ញុំឈប់នៅនេះទៅនៅ ១០០១ កាលឆ្នាំ៨០!

ដារ៉ា : បារ៉ៃហ្នឹងកងខាងណា?

លន់ : ពួកសឺន សាន ឬពួកអ៊ិនតាន!

ដារ៉ា : អញ្ចឹងគេឲ្យតាសឿន ទៅនៅ១០០២ហ្នឹង?

លន់ : បាន០២ខែ គាត់ខ្លាចរត់ទៅបារ៉ៃ!

ដារ៉ា : ខាងសឺន សាន ឬក៏អ៊ិនតាន?

លន់ : មិនដឹងបើខ្ញុំទៅនៅ១០០១ហើយហ្នឹង!

ដារ៉ា : ពេលដកតាសឿន ហើយអញ្ចឹងអ្នកណាគេឡើងជំនួសតាសឿននៅ៨០៨ហ្នឹង?

លន់ : មិនដឹងទេ! ព្រោះខ្ញុំបែកទៅហើយ ខ្ញុំទៅមុនតាសឿន ទៀត ហើយតាសឿន ហ្នឹងគេឲ្យនៅរៀនកងអន្តរាគមនៅ១០០៣!

ដារ៉ា : អ្នកណាគេឡើងជំនួសតាសឿននៅ៨០៨ហ្នឹង?

លន់ : ០៦ឆ្នាំក្រោយមកបានខ្ញុំមកដល់នេះវិញ បានដឹងថាតាភាព ហើយតាគង់ ហើយម្ដងនេះគេឲ្យអង្គភាពមានលេខច្បាស់!

ដារ៉ា : ឈ្មោះអី?

លន់ : កងពល៩១២!

ដារ៉ា : ប្រកណាបើកមុនគេ ៨០៨, ១០០១, ១០០២, ១០០៣?

លន់ : ៨០៨មុនគេ ហើយបានទៅ១០០១, ១០០២, ១០០៣!

ដាវ៉ា ៈ ពូធ្វើអីនៅ១០០១?

លន់ ៈ ទៅតាមអង្គភាពចាស់!

ដាវ៉ា ៈ អង្គភាពណា?

លន់ ៈ នៅជាមួយកែវ ពក ទទួលភូមិភាគឧត្តរ ។

ដាវ៉ា ៈ ឆ្នាំណាពូទៅដល់១០០១?

លន់ ៈ ឆ្នាំ៨០ ខែ០៦-០៧-០៨-០៩ ។

ដាវ៉ា ៈ មុនហ្នឹងមានគេរៀបចំអីហើយទេ?

លន់ ៈ គេកើតជាប្រកអស់ហើយ មកទាំងអស់អង្គភាពពីរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង ។

ដាវ៉ា ៈ អ្នកណាទទួលខុសត្រូវនៅ១០០១?

លន់ ៈ កាលនោះខ្ញុំមិនសូវយល់ទេ ព្រោះថាខ្ញុំអ្នកមកថ្មី តែដោយឡែក១០០១ហ្នឹងមានដឹកនាំច្រើនណាស់ដែរ ដឹងថាកកើតរបស់របរអីនៅឃាំងតាដុះ ប៉ុណ្ណឹងទេ!

ដាវ៉ា ៈ ហើយនៅ១០០១ហ្នឹងទទួលខុសត្រូវប៉ុន្មានកងទ័ពទៅ?

លន់ ៈ មាន៨០១, ៩២០ និងពួកភូមិភាគកណ្តាល!

ដាវ៉ា ៈ ៨០១ នេះអ្នកណាប្រធានកងពល?

លន់ ៈ តាសារឿន និងតាសឺន សាន!

ដាវ៉ា ៈ ចុះ៩២០?

លន់ ៈ តាសាន ហៅតា០៦!

ដាវ៉ា ៈ ចុះពួកភូមិភាគកណ្តាល?

លន់ ៈ តាពក គាត់ទទួលរួមទាំងអស់!

ដាវ៉ា ៈ ចុះអ្នកណានៅពីលើតាសារឿន តាសឺន សាន និងតាពក?

លន់ ៈ នៅហ្នឹងតាសុន សាន!

ដាវ៉ា ៈ កាលហ្នឹងពូធ្វើអី?

លន់ ៈ ធ្វើជាយុទ្ធជនធម្មតា ហើយខែ០៤ ឆ្នាំ៨១ គេឲ្យខ្ញុំទៅនៅកំពង់ចាម!

ដាវ៉ា ៈ ពូនៅកងណា?

លន់ ៈ វរសេនាតូច៤១ កងពិសេស១០៥ នៅភូមិភាគកណ្តាល ហើយក្រោយមោបាន១០១ ហើយក្រោយមោទៀតបានបញ្ចូលជាកងពល៤១៧វិញ មានបែកពី១០០១មកហើយ នៅឆ្នាំ១៩៨៥ ហើយ១៩៨៦បានខ្ញុំឡើងមកវិញ ហើយ១៩៨៣ឡើងមកម្តង ហើយនៅ

ពេលដែលខ្ញុំឡើងមោ១០០១ ជរុំនៅជាយដែនហ្នឹងគេវៃបែកអស់ហើយមិនមាននៅលើទឹកដីយើងទេ ទៅនៅលើទឹកដីគេវិញ!

ដារ៉ា ៖ នៅក្នុងកងពិសេសពួហ្នឹងអ្នកណាជាប្រធាន?

លន់ ៖ អៀង ឆាំ គាត់ស្លាប់ហើយ!

ដារ៉ា ៖ ឆ្នាំណាបង្កើតកងពល៤១៧?

លន់ ៖ នៅឆ្នាំ១៩៨៣!

ដារ៉ា ៖ ការដាក់លេខកងពលហ្នឹងវាពាក់ព័ន្ធនឹងអីដែរ?

លន់ ៖ ៩៨០, ៩១២ អាហ្នឹងវាទាក់ទងនឹងខែថ្ងៃរបស់គេ ដល់ខ្ញុំនេះខ្ញុំមិនយល់!

ដារ៉ា ៖ បើខ្ញុំដឹងមកវាបង្កើតឡើងនៅថ្ងៃ០៤ ខែ០១ ឆ្នាំ៨៧ អញ្ចឹងវាមិនមានការពាក់ព័ន្ធទេ?

លន់ ៖ ហ្នឹងហើយ!

ដារ៉ា ៖ អញ្ចឹងពូច្បាស់ហើយកងពល៤១៧ កើតនៅឆ្នាំ៨៣?

លន់ ៖ ៨៣!

ដារ៉ា ៖ អញ្ចឹងឡើងពីកំពង់ចាមមក?

លន់ ៖ បាទ! តែមិនបានឡើងមោ១០០១ទេ គឺឆ្នាំ១៩៨៦ឡើងមោ៨០៨នេះ ហើយដល់ពេលចុះមកវិញបាន ជួបអង្គភាពចាស់ខ្ញុំសុទ្ធតែមេៗខ្ញុំ ហើយខ្ញុំក៏សុំគេទៅនៅអង្គភាពចាស់របស់ខ្ញុំនៅ៩១២វិញ!

ដារ៉ា ៖ ៩១២ ហ្នឹងតាភាព ជាប្រធានកងពល?

លន់ ៖ ហ្នឹងហើយ!

ដារ៉ា ៖ អីភាព?

លន់ ៖ អន សុភាព!

ដារ៉ា ៖ ៩១២កើតឆ្នាំណា?

លន់ ៖ មិនដឹងពីឆ្នាំណាទើបតែខ្ញុំចូលអង្គភាពចាស់នេះគេថា៩១២!

ដារ៉ា ៖ អញ្ចឹងអាចឆ្នាំ៨៦?

លន់ ៖ អាចមុនហ្នឹង!

ដារ៉ា ៖ ព្រោះនៅ១០០១ហ្នឹងឆ្នាំ៨៥?

លន់ ៖ វៃបែកទាំងអស់!

ដារ៉ា ៖ ពេលវៃបែកទាំងអស់អញ្ចឹងទ័ពខ្មែរក្រហមទៅនៅណា?

លន់ ៖ បើប្រុសៗនៅតាមមុខសញ្ញានៅសមរភូមិ និងស្រីៗនៅខាងក្នុងខាងជំរុំខ្មែរក្រហម ដោយមួយផ្នែកនៅខាងកើតនោះ១០០១នោះគេហៅថាពួក “៣ ០៧” ហើយពួកនៅខាងលិចនេះ ១០០៣គេហៅពួក៨០ ហើយពួក៩១២នេះគេហៅពួកអូរបន្ទូរ!

ដារ៉ា ៖ ចុះជំរុំហ្នឹងម៉េចដែរ?

លន់ ៖ ១០០១នោះគេហៅថាជំរុំ “៣ ០៧”នៅស៊ឹងចន្ទ ហើយ១០០៣គេហៅថាជំរុំ៨០នៅអូរធំ ហើយពួក៩១២ នេះគេហៅថាជំរុំអូរបន្ទូរ!

ដារ៉ា ៖ ជំរុំនៅស៊ឹងចន្ទនេះអ្នកណាគ្រប់គ្រងរួម?

លន់ ៖ តាពក!

ដារ៉ា ៖ ចុះជំរុំ៨០?

លន់ ៖ មិនដឹង!

ដារ៉ា ៖ ចុះ១០០៣ តាម៉ុក គ្រប់គ្រង?

លន់ ៖ តាម៉ុក គ្រប់គ្រងពលើហ្នឹងទាំងអស់ក្រោយពីបែកបាក់មក!

ដារ៉ា ៖ ជំរុំអូរបន្ទូរ?

លន់ ៖ តាគង់ គ្រប់គ្រងរួម!

ដារ៉ា ៖ បែកបាក់ជំរុំទាំង០៣ហ្នឹងនៅឆ្នាំណា?

លន់ ៖ ១៩៨៥ លែងមាននៅលើទឹកដីខ្មែរហើយទៅនៅលើទឹកដីថៃទាំងអស់!

ដារ៉ា ៖ ឆ្នាំ៨៦-៨៧ហ្នឹងមានព្រឹត្តិការណ៍អីទៀត?

លន់ ៖ កងនារីៗគេដឹកជញ្ជូនគ្រាប់ ស្បៀង និងប្រុសៗនៅតាមមុខសញ្ញាគេនៅសមរភូមិ!

ដារ៉ា ៖ ការដឹកជញ្ជូនហ្នឹងមានផ្លូវគេទេ?

លន់ ៖ មានគេទាក់ទងតាមខ្សែរយៈដូចថា ពួក “៣ ០៧”ឡើងមកទាក់ទងនឹងពួក៨០ ហើយពួក៨០ ឡើងមោទាក់ទងនឹងពួកអូរបន្ទូរហ្នឹង!

ដារ៉ា ៖ ការទាក់ទងហ្នឹងគេប្រើមធ្យោបាយអី?

លន់ ៖ គេប្រើទូរលេខ!

ដារ៉ា ៖ ចុះជំរុំនេះនៅពេលណា?

លន់ ៖ ឆ្នាំ១៩៨៨ ក្រោយពីការដកកងទ័ពវៀតណាមទៅ បានពួកខ្មែរក្រហមវៃទាំងអស់មកនៅនេះ ដូចនៅអន្លង់វែងនេះ ហើយនៅត្រពាំងប្រាសាទហ្នឹងក៏ដូចគ្នា!

ដារ៉ា ៖ អញ្ចឹងមានតែខ្មែរក្រហមដឹងពីផែនការដកកងទ័ពវៀតណាមនៅឆ្នាំ៨៩ហ្នឹង អញ្ចឹងខ្មែរក្រហមវៃហ្នង?

លន់ ៖ វៃជាទ្រនុងទ្រាយធំពីមុំ០៣ ទៅប៉ៃលិន ហើយឈប់នៅលើទឹកដីថៃមកនៅលើទឹកដីខ្មែរវិញ កាលហ្នឹងជាផែនការរបស់តាម៉ុក!

ដារ៉ា ៖ អញ្ចឹងមខសញ្ញាមួយៗចុះមកតាមណា?

លន់ ៖ គេទៅតាមមុខសញ្ញាដែលគេទទួលខុសត្រូវ ហើយ៩៤-៩៥-៩៦ចាប់ផ្ដើមបោះឆ្នោតជ្រើសរើសរៀបចំដឹកនាំមូលដ្ឋាន!

ដារ៉ា ៖ ជំរុំទាំង០៣ចុះមោនេះ ហើយតាពក គាត់ទៅនៅណា?

លន់ ៖ នៅឃុំថ្វាត!

ដារ៉ា ៖ ចុះ «៣ ០៧»?

លន់ ៖ នៅត្រពាំងប្រាសាទ ខាងតា០៥ តា០៦ ហើយពក៩១២នៅខាងកើតអន្លង់វែងមកខាងនេះ!

ដារ៉ា ៖ ខាងលំទង?

លន់ ៖ បាទ!

ដារ៉ា ៖ ចុះ៤០?

លន់ ៖ ៤០ពួក១០០៣គេហៅថាពួក៩៨០ ៧៨៥ សព្វថ្ងៃនៅអន្លង់វែងយើងនេះនៅភូមិថ្មល់កែង!

ដារ៉ា ៖ ទីរួមស្រុក?

លន់ ៖ បាទ!

ដារ៉ា ៖ នៅពេលខ្មែរក្រហមមិនបានបោះឆ្នោតនៅឆ្នាំ៩៣ហ្នឹង អញ្ចឹងកាលហ្នឹងខ្មែរក្រហមធ្វើអី?

លន់ ៖ កងទ័ពនៅខាងមុខតាមមុខសញ្ញាទៅ ហើយគ្រួសារនៅខាងក្រោយគិតតែខំធ្វើស្រែចម្ការ!

ដារ៉ា ៖ អញ្ចឹងមិនបានទៅបោះឆ្នោតទេ?

លន់ ៖ មិនបានទេ មិនមានឈ្មោះបោះឆ្នោតផងហ្នឹងៗ

ដារ៉ា ៖ ចុះ០៣ផ្នែកហ្នឹងគេរៀបចំម៉េចទៅ?

លន់ ៖ ពីដើមមិនមានជាការចាត់តាំង ហើយក្រោយមោទៅជាការបោះឆ្នោតជ្រើសរើសមេភូមិ មេឃុំៗ

ដារ៉ា ៖ បោះឆ្នោត?

លន់ ៖ បោះឆ្នោតខ្មែរក្រហម!

ដារ៉ា ៖ កាលមុនគេចាត់តាំងយ៉ាងម៉េច?

លន់ ៖ ចាត់តាំងតាមខ្សែអង្គភាព ហើយការបោះឆ្នោតនេះមិនមែនតាមខ្សែអង្គភាពទេ!

ដារ៉ា ៖ រៀបចំតាមខ្សែអង្គភាពយ៉ាងម៉េច?

លន់ ៖ អាហ្នឹងគេមានយូរមកហើយនៅក្នុងអង្គភាពមួយមេៗគេធ្វើការនៅខាងមុខ ហើយនៅខាងក្រោយនេះមានអ្នកណាធ្វើការនៅក្រោយជាសមាជិក ជាប្ដី ជាប្រពន្ធ គេចាត់តាំងឲ្យធ្វើការនៅក្រោយអាហ្នឹងគេសំដៅទៅលើអង្គភាព ហើយសំដៅទៅលើមនុស្សៗណាដែលគេទុកចិត្ត!

ដារ៉ា ៖ ហើយក្រោយមោឆ្នាំ៩៥នេះមានការបោះឆ្នោត?

លន់ ៖ ក្រោយមកនេះតាម៉ុក ធ្វើឲ្យមានការជ្រើសរើសថ្នាក់មូលដ្ឋាននៅស្រុកអន្លង់វែងនេះដោយការបោះឆ្នោត!

ដារ៉ា ៖ ដូចយើងបោះឆ្នោតឥឡូវដែរ?

លន់ ៖ ដូចគ្នា!

ដារ៉ា ៖ កាលឆ្នាំ៨៨ ពេលចុះមកពូនៅកងពល៩១២ អញ្ចឹងពូចុះមកនៅលំទងនេះ?

លន់ ៖ កាលនោះនៅតែលើភ្នំនៅឡើយទេ ដល់ចុងឆ្នាំបានរំដោះបាននៅនេះបានរៀបចំភូមិនៅនេះ ហើយខ្ញុំនៅសមរភូមិមុខទេ នៅជាមួយ ទុយ ប៉ុនរ៉េត ហើយក្រោយពីតាភាព ស្លាប់ទៅក៏ឡើងទៅជាកងពលដែរ!

ដារ៉ា ៖ គាត់មានតួនាទីអីដែរ?

លន់ ៖ ប្រធានកងពល៩១២ ព្រោះតាភាព ស្លាប់ហើយ តាហេង ស្លាប់ហើយ ក៏ឡើងជាប្រធានទៅបន្ទាប់ពីតាគង់!

ដារ៉ា ៖ តាភាព ហ្នឹងស្លាប់ដោយសារអី?

លន់ ៖ កើតទៀក!

ដារ៉ា ៖ តាគង់ គាត់នៅ?

លន់ ៖ បាទ! ចាប់ពីនោះមោមានតាភាព តាហេង តាគង់ បានមកដល់តារ៉េត ប៉ុន្ដែស្លាប់បន្ដបន្ទាប់គ្នា បានឡើងតារ៉េត និងតាគង់ នៅកងពល៩១២ហ្នឹង!

ដារ៉ា ៖ តារ៉េត នេះឡើងទៅជាអីវិញ?

លន់ ៖ តាគង់ ប្រធាន និងតារ៉េត អនុ ហើយមិនយូរប៉ុន្មានតារ៉េត គាត់ផ្ដាច់ខ្លួនទៅនៅខាងក្នុងៗ

ដារ៉ា ៖ នៅឆ្នាំណា?

លន់ ៖ ឆ្នាំ៩៦!

ដារ៉ា ៖ តារ៉េតហ្នឹងមានដាប់ខ្សែខាងណាអីទេ?

លន់ ៖ គាត់អ្នកភូមិនៅក្បែរខ្ញុំទេនៅព្រៃញ៉ែរ ហើយប្អូនគេនោះខ្មែរខ្ញុំរត់បាត់ហើយ ក្រោយមកនៅកងពល ហើយក្រោយមកមកភូមិភាគវិញ ហើយឥឡូវគាត់ស្លាប់ហើយ!

ដារ៉ា ៖ ដោយសារ?

លន់ ៖ ដោយជម្ងឺ!

ដារ៉ា ៖ ឆ្នាំណា?

លន់ ៖ ឆ្នាំហ្នឹង ២០០១!

ដារ៉ា ៖ កាលហ្នឹងពូមានជាប់ឆ្នោតអីទេ?

លន់ ៖ ជាប់ឆ្នោតជាមេភូមិតាំងពីពេលនោះមោ!

ដារ៉ា ៖ តាំងពី៩៥?

លន់ ៖ បាទ!

ដារ៉ា ៖ មេភូមិអី?

លន់ ៖ លំទងចាស់!

ដារ៉ា ៖ ឆ្ងាយទេ?

លន់ ៖ ប្រហែល១០គីឡូ!

ដារ៉ា ៖ ៩៥ ពូនៅមេភូមិនៅលំទងចាស់?

លន់ ៖ បាទ! កាលនោះមិនយើងអាចមករស់នៅដូចសព្វថ្ងៃនេះទេ កាលនោះរស់នៅជើងភ្នំស្រុកនោះទេ ក្រោយពីបោះឆ្នោតហើយបានចាប់ផ្ដើមបំបែកភូមិមកវិញ ហើយក្រោយសមាហរកម្មហើយបានឲ្យឈ្មោះភូមិជាដូវការ!

ដារ៉ា ៖ ក្នុងពេលពូធ្វើនិរសារ ពូមានដែលធ្លាប់ឮឈ្មោះមេដឹកនាំខ្មែរក្រហមទេ?

លន់ ៖ ប៉ុល ពត, អៀង សារី, ខៀវ សំផន មិនដែលឃើញមុខទេ។

ដារ៉ា ៖ ពេលវៀតណាមវ៉ៃតាំងពីឆ្នាំ ៨០-៩៥ តើឈ្មោះដឹកនាំទាំងអស់ហ្នឹងនៅតែឮឈ្មោះទៀតឬក៏ យ៉ាងម៉េច?

លន់ ៖ ឮរហូតដល់ឃើញមុខទៀត។

ដារ៉ា ៖ បើធៀបជាមួយតាម៉ុក អ្នកណាខ្ពស់ជាង?

លន់ ៖ នៅតែប៉ុល ពត, អៀង សារី, ខៀវ សំផន គេទទួលខាងក្រៅ រីឯតាម៉ុក ទទួលខាងក្នុង។

ដារ៉ា ៖ ចុះតាំងពី៩៥មោហ្នឹងមានព្រឹត្តិការណ៍អីកើតឡើងទៀត?

លន់ ៖ គេហៅថាមានជម្លោះធំរវាងមេដឹកនាំខ្មែរក្រហម រហូតដល់មានការសម្លាប់គ្នា ដូចជាសម្លាប់តាសុន សេន ដូចជាតាម៉ុក បញ្ជូនអង្គភាពទៅវ៉ៃប៉ុល ពត ហើយវ៉ៃ០៥, ០៦ នៅឆ្នាំ៩៧ ហើយមិនយូរប៉ុន្មានបានរដ្ឋាភិបាលវ៉ៃបែកហើយរត់ទៅស្រុកថៃនៅភូណយ ហើយឆ្នាំ៩៨ មានការចរចារគ្នាត្រឹមត្រូវហើយបានមានសមាហរណកម្មទៅ!

ដារ៉ា ៖ នៅ០៥-០៦ កក្កដា ៩៧ មានបានប្រទះគ្នាជាអាវុធ ចុះនៅអន្លង់វែង?

លន់ ៖ អន្លង់វែងមុនហ្នឹងទៀតមុនវ៉ៃប៉ុល ពត!

ដារ៉ា ៖ មុនប៉ុន្មានថ្ងៃនៅថ្ងៃ០៥-០៦ កក្កដា?

លន់ ៖ ខែ០២-ខែ០៣ ហើយខែ០៦-០៧ បានពួខាងនោះម្ដង!

ដារ៉ា ៖ មូលហេតុអីបានបង្កឲ្យមានជម្លោះហ្នឹង?

លន់ ៖ ខ្ញុំនៅតែមេភូមិនៅនេះ ហើយក្រោយហ្នឹងក៏ពួថាព្រឹត្តិការណ៍វ៉ៃគ្នាទៅ ហើយពួគេសម្លាប់តា សុន សេន ហើយអ្នកណាជាអ្នកសម្លាប់? ពួថាតា០៥-០៦ ហើយបានតាម៉ុក បញ្ជាឲ្យកម្លាំងទៅជួយហើយទៅដល់ខាងនោះប៉ុល ពត ទៅនៅខាងតា០៥-០៦ ហើយក៏បញ្ជាកម្លាំងនៅខាងនោះវ៉ៃទៅ រហូតចាប់បាននៅអូរស្វាយ ហើយយកមកវិញបានខ្មែរក្រហមខាងមូលដ្ឋាននេះគេកាត់ទោសខ្មែរក្រហមតាពក ហ្នឹង!

ដារ៉ា ៖ អញ្ចឹងមានន័យថាគ្មានអ្នកណាដឹងពីមូលហេតុដែលប៉ុល ពត, តា០៥-០៦ មានជម្លោះជាមួយតាម៉ុក ទេ?

លន់ ៖ នៅតែមិនដឹង!

ដារ៉ា ៖ អញ្ចឹងគ្មានអ្នកណាដឹង?

លន់ ៖ ព្រោះថាខ្ញុំនៅឆ្ងាយដាច់ពីគេ!

ដារ៉ា ៖ នៅ១០០៣, ៧៨៥ ហ្នឹងសុទ្ធតែកងពលនៅក្រោមតាម៉ុក?

លន់ ៖ សរុបទៅនៅតាមជំរុំហ្នឹងនៅក្រោមតាម៉ុក ទាំងអស់!

ដារ៉ា ៖ អ្នកណានៅស្គាលជាង?

លន់ ៖ ប្រហែលជា៩៨០!

ដារ៉ា ៖ កាលហ្នឹង៩៨០អ្នកណាមេកងពល?

លន់ ៖ តាឃឹម សាន ពួកគ្នាគេហ្នឹងហើយ!

ដារ៉ា ៖ ពេលពូធ្វើជាមេភូមិហ្នឹង ពូមានឮពាក្យចចាមរាមអីទេពីការសម្លាប់សុន សេន?

លន់ ៖ ខ្ញុំនៅដាច់ពីគេ គ្រាន់តែទទួលដំណឹងថាមានការក្បត់គ្នាហើយ ដល់អញ្ចឹងគេឲ្យយើងក្ដោបកម្លាំងឲ្យជាប់កុំឲ្យមានការច្របូកច្របល់ មានតែប៉ុណ្ណឹងទេ!

ដារ៉ា ៖ បើពូជាមេភូមិចុះនៅក្នុងទាហានពូមានតួនាទីជាអីវិញ?

លន់ ៖ នៅក្នុងអង្គភាពមួយមានកម្លាំងជាប្រុសៗនៅមុខ ហើយស្រីនៅខាងក្រោយៗ ហើយនៅខាងនេះគេឲ្យបង្កើតជាភូមិតាំងពីសម័យ៩៥ហ្នឹង ហើយមេភូមិទទួលខុសត្រូវតាមអង្គភាព ដូចជាខ្ញុំនៅនេះអញ្ចឹងក្នុងកងវរ៥១-៥២!

ដាវ៉ា ៖ ព្រឹត្តិការណ៍ផ្តាច់ខ្លួនចុងក្រោយនេះដោយមានការរត់ទៅភូណាយនេះ វាយ៉ាងម៉េចវិញ?

លន់ ៖ ដូចជាក្តោបមិនបានដែរ គិចខាងនោះផ្តាច់ខ្លួនហើយ ហើយបានខាងរដ្ឋាភិបាលចាប់ផ្តើមវ៉ៃមកបណ្តោយ ហើយដល់វ៉ៃមកហ្នឹងពួកខ្ញុំទៅខាងទំបន់ថ្មីទៅខាងល្មៀត ពេលនេះរត់ទៅដល់រត់ទៅ គេថាទៅមិនបានទេក៏មកខាងនេះវិញ ហើយខាង៩៨០ និងត្រពាំងប្រាសាទគេទៅនោះ ហើយខ្ញុំមកនេះនៅបាយតាប នៅភូណាយ!

ដាវ៉ា ៖ នៅភូណាយហ្នឹងក្រោមតាម៉ុក?

លន់ ៖ បាទ!

ដាវ៉ា ៖ ហើយខាងភូណាយចុះមកខាងបាយតាបហ្នឹងរួបរួមជាមួយគ្នាទេ?

លន់ ៖ មានការចរចាគ្នា គេថាពួកយើងចុះមោជ្រលក់ដៃ!

ដាវ៉ា ៖ ចរចាជាមួយអ្នកណា?

លន់ ៖ ទេព ប៊ុនណាល ។

ដាវ៉ា ៖ ពេលឡើងទៅភូណាយហ្នឹងមានកងពលទៅជាមួយទេ?

លន់ ៖ ទៅមុនដំបូងសុទ្ធតែគ្រួសារ ហើយប្រហែល០២ខែមោមានគ្រប់គ្នាទៅ ។

ដាវ៉ា ៖ កងពលណាខ្លះឡើងទៅដល់ភូណាយ?

លន់ ៖ ៩១២, ៩២០, ១០៥, ៨០១ខ្លះដែរ, ៩៨០ខ្លះដែរ ហើយផ្តាច់ខ្លួនទៅខាងក្នុងនោះដូចគ្នា!

ដាវ៉ា ៖ កងពលទាំងអស់ហ្នឹងអ្នកណាធំជាងគេបន្ទាប់ពីតាម៉ុកមក?

លន់ ៖ ៩១២ តាគង់!

ដាវ៉ា ៖ ចុះ៩២០?

លន់ ៖ មិនដឹងអ្នកណាទេ ព្រោះមេៗគេងាប់អស់ហើយ!

ដាវ៉ា ៖ ចុះ១០៥?

លន់ ៖ មិនដឹងទេ ខ្លះទៅក្នុងហើយ!

ដាវ៉ា ៖ ចុះ៨០១?

លន់ ៖ បែកបាក់អស់ហើយ!

ដាវ៉ា ៖ ចុះ៩៨០នេះអ្នកណាឡើងទៅដល់ភូណាយ?

លន់ ៖ មិនមានទេ!

ដាវ៉ា ៖ អញ្ចឹងមានន័យថាឡើងទៅដល់ភូណាយ មានតែកងពល៩១២ទេឡើងទៅមានមេកងពល? មានផែនការយ៉ាងម៉េចបានចុះពីភូណាយមកចាប់ដៃវិញ?

លន់ ៖ មេគេចុះមកធ្វើការបរបោរដើម្បីបញ្ចប់សង្គ្រាម!

ដារ៉ា ៖ អញ្ចឹងនៅភូណយអ្នកណាតំណាងមកចរចារ?

លន់ ៖ ទេព ប៉ុនណាល!

ដារ៉ា ៖ ចុះខាងក្រោមនេះអ្នកណាមកចរចារ?

លន់ ៖ តាមការដឹងថាតា ទា បាញ់ ហ្នឹងមកចរចារនៅព្រះវិហារ!

ដារ៉ា ៖ មុនមកចរចារនេះឮថាតាម៉ុក មានប្រជុំដែរ?

លន់ ៖ ប្រជុំរាល់ថ្ងៃ!

ដារ៉ា ៖ ប្រជុំរឿងអី?

លន់ ៖ ការចរចារហ្នឹង!

ដារ៉ា ៖ រាល់ប្រជុំម្តងៗអ្នកណាដឹកនាំ?

លន់ ៖ ស្តាប់មេៗគេហ្នឹង!

ដារ៉ា ៖ មានលើកជាគំនិត ជាផែនការអីទេ?

លន់ ៖ មិនមានលើកអីទេ ។

ដារ៉ា ៖ តាមខ្ញុំឮការចូលរួមចរចាហ្នឹងគឺដើម្បីចូលរួងស៊ីផ្ទៃក្នុង?

លន់ ៖ មិនដឹងទេ និយាយរួមតាំងពីបែកអន្លង់វែងមកខ្ញុំមិនដែលបានឃើញតាម៉ុក និងមេដឹកនាំខ្មែរក្រហមទេ!

ដារ៉ា ៖ គឺថាប្រធានភូមិប្រធានឃុំដែលចុះមកពីភូណយហ្នឹងធ្វើយ៉ាងម៉េចឲ្យមានឥទ្ធិពលមកប្រធានភូមិប្រធានឃុំដែលមានស្រាប់នៅអន្លង់វែងយើង?

លន់ ៖ មិនមានគំនិតអីដែលបង្ករឲ្យមានអថេរភាពនោះទេ ព្រោះថាចុះមកដំបូងវាស្មើរតែដូចនឹងសព្វថ្ងៃ ហើយដូចជាមិនមានសកម្មភាពអី តែក្រោមពីបានរួមគ្នាមកមានតែចោរឆក់ និងចោរប្លន់ទេ!

ដារ៉ា ៖ ពូ ជាប្រធានភូមិដែលបានចាត់តាំងមកហ្នឹងអញ្ចឹងពូធ្វើម៉េចដើម្បីកសាងកម្លាំងជាមួយភូមិនៅនេះឲ្យមានកម្លាំងឡើងវិញ?

លន់ ៖ គោលការណ៍មិនមានទេ ព្រោះថាមេភូមិនៅភូណយមកដល់នេះធ្វើមេភូមិទៅ ។

ដារ៉ា ៖ នៅឆ្នាំណាពូចុះមោជ្រលក់ដៃគ្នា?

លន់ ៖ ឆ្នាំ៩៨ ។

ដារ៉ា ៖ ពេលហ្នឹងគេមានរៀបចំបោះឆ្នោតសាកលឆ្នាំ៩៨ ពូ មានបានទៅបោះឆ្នោតទេ?

លន់ ៖ មិនបានទេ ពួកនៅបាយតាបបានបោះ ហើយពួកនៅភូណយមិនបានបោះទេ!

ដារ៉ា ៖ ពូអាចធៀបបានទេថាពីការផ្លាស់ប្តូរយ៉ាងម៉េចដែរកាលពីមិនទាន់សមាហរណកម្ម និងក្រោយសមាហរណកម្ម?

លន់ ៖ កាលពីខ្ញុំនៅសម័យតាម៉ុក នេះពួកខ្ញុំមានគុណធម៌ និងសីលធម៌ ចេះយល់ធុរៈគ្នា ចេះសាមគ្គីគ្នា ចេះចែករំលែកគ្នា ហើយក្រោយពីសមាហរណកម្មមករស់នៅក្នុងសង្គមនេះមានឯករាជ្យហើយ ខ្ញុំមានការអថេរភាពជាច្រើននៅភូមិឃុំនេះកន្លងមក ។

ដារ៉ា ៖ បញ្ហាអីខ្លះ?

លន់ ៖ ចោរឆក់ ចោរប្លន់ ហើយក្រោយពីអាពួកនេះមានអាពួកបោសប្រាស់ និងក្រោយមកពួកញៀនយ៉ាទៀត អញ្ចឹងដល់ខ្ញុំពិនិត្យឃើញថាវាចេះតែប្រែប្រួលរហូត!

ដារ៉ា ៖ ចុះបញ្ហាជីវភាពនៅក្នុងស្រុកអន្លង់វែងនេះវិញ?

លន់ ៖ បើនិយាយពីការដាំដុះវិញមិនមានការភ័យព្រួយអីទេ ព្រោះវាមានទុនរួចជាស្រាច់ ហើយសុវត្ថិភាពហ្នឹងដូចជាមិនសូវភ័យព្រួយអីដែរ ហើយលុយពីធនាគារក៏មិនសូវយកដែរ គឺខ្លួនទីពឹងខ្លួន!

ដារ៉ា ៖ មានអ្នកចំណូលថ្មីទេ?

លន់ ៖ មានច្រើនកាលពីដើមមានតែ១០០គ្រួសារទេ ហើយមកដល់ឥឡូវនេះមាន២០០គ្រួសារ ។

ដារ៉ា ៖ កត្តាអីបានជំរុញឲ្យមានការមករស់នៅនៅនេះ?

លន់ ៖ ដោយសារតែសេដ្ឋកិច្ចស្រុកមិនល្អ ខ្វះជាដីអីអញ្ចឹងទៅ ហើយខ្លះមករកដីទូលាយ នងរកស៊ីបាន ហើយសុំផ្លាស់លំនៅមក!

ដារ៉ា ៖ អ្នកចំណូលថ្មីហ្នឹងទាក់ទងនឹងបញ្ហាអីដែរ?

លន់ ៖ បាត់មាន់ បាត់ឆ្កែ មិនឲ្យយើងទុកចិត្តវា!

ដារ៉ា ៖ ពូស្គាល់តាម៉ុក ប៉ុន្មានដែរ?

លន់ ៖ បើនិយាយពីស្គាល់តាម៉ុក ខ្ញុំឆ្ងាយណាស់ ព្រោះថាបើនិយាយទៅប្រជុំអប់រំជាមួយតាម៉ុក គឺតែពាដងទេ!

ដារ៉ា ៖ ប្រជុំពាដងពីរឿងប៉ុន្មានអីខ្លះ?

លន់ ៖ លើកទី៣ រឿងជំនាន់ដោះស្រាយរឿងតាសៀនហ្នឹងម្តង មិនបាច់សម្លាប់វាទេ ឲ្យវាបង្កើតកូនទៅ រឿង០២ ដងរឿងគ្រួសារកងទ័ពដែលកាលនោះខ្ញុំនៅជាមេភូមិ បើកផ្ទះម្នាក់ មួយខ្នងហើយគោមេម្នាក់មួយនឹម ឬមួយគ្រួសារមួយ លើកទី០៣ ឲ្យភូមិមួយបង្កើតសាលា ដើម្បីឲ្យក្មេងរៀន ។

ដារ៉ា ៖ អញ្ចឹង ពូគិតតាម៉ុក ជាមនុស្សម៉េច?

លន់ ៖ តាម៉ុក គាត់មិនអាក្រក់ទេ ។

ដារ៉ា ៖ របស់ហ្នឹងគាត់បានមកពីណា?

លន់ ៖ បានមកពីថៃជំនួយមក ។

ដារ៉ា ៖ ជំនួយហ្នឹងមានការដោះដូរអីទេ?

លន់ ៖ ខ្ញុំមិនដឹងដែរ ។

ដារ៉ា ៖ ចុះដឹកនាំផ្សេងៗពួយល់ថាម៉េច?

លន់ ៖ ដូចថាឆ្ងាយណាស់ បើនិយាយពីរឿងប្រជុំវិញនិយាយតែពីរឿង សីលធម៌ គុណធម៌ សច្ចៈធម៌ មិនឲ្យកាប់សម្លាប់ មិនឲ្យលួច មិនឲ្យកាត់ក្បាលអ្នកគា និយាយរួមទ្រឹស្តីល្អជាទីបំផុត ហើយសីលធម៌១២ប្រការអីហ្នឹងសុទ្ធតែមានហើយ ។

ដារ៉ា ៖ សីលធម៌១២ប្រការហ្នឹងមានតាំងពីពេលណាមក?

លន់ ៖ មានយូរហើយ ហើយក្រោយមកក៏រក្សាអាហ្នឹងជាប់ជានិច្ចដែរ!

ដារ៉ា ៖ ចុះបើមានទ្រឹស្តីល្អអញ្ចឹងក្រោយមកឆ្នាំ៧៩ហ្នឹងម៉េចបានមានការបាត់ខ្លួន និងការចាប់ខ្លួន?

លន់ ៖ ឧទាហរណ៍ ខ្ញុំនៅនេះខ្ញុំមិនដឹងគេគេកាប់សម្លាប់បងប្អូនខ្ញុំនៅក្នុងទេ ហើយឪពុកមាខ្ញុំធ្វើជាចៅហ្វាយស្រុកនៅភ្នំសំពៅ គេចោទថាខ្សែក្បត់គេកាប់ចោលទៅ!

ដារ៉ា ៖ សម្លាប់នៅរបបណា?

លន់ ៖ របបពាឆ្នាំហ្នឹង!

ដារ៉ា ៖ របបពាឆ្នាំអ្នកណាដឹកនាំ?

លន់ ៖ ជាពួក!

ដារ៉ា ៖ ពួកហ្នឹងមានតាម៉ុក ទេ?

លន់ ៖ មាន!

ដារ៉ា ៖ ចុងក្រោយពូថាតាម៉ុក ជាមនុស្សល្អ?

លន់ ៖ ល្អត្រង់ថាមកនៅអន្លង់វែងនេះ ហើយនៅក្រៅពីហ្នឹងខ្ញុំមិនដឹងទេ ។

ដារ៉ា ៖ ភាគីនយោបាយណាខ្លះដែលជាប់ពាក់ព័ន្ធនឹងរឿងអន្លង់វែងនេះ?

លន់ ៖ បក្សគេធ្វើតាមបក្សគេទៅ ហើយបក្សយើងធ្វើតាមបក្សយើងទៅ ។

ដារ៉ា ៖ អ្នកនៅអន្លង់វែងនេះមានចិត្តគំនិតយ៉ាងម៉េចជាមួយថៃ?

លន់ ៖ ដូចជាមិនមានមនោសញ្ចេតនាអីទេ!

ដារ៉ា ៖ គាត់នៅមានការបារម្ភពីប្រទេសយើង និងថៃទេ?

លន់ ៖ បើសិនណាមានជាជម្លោះ និងសង្គ្រាមមានការភ័យព្រួយជាច្រើន!

ដារ៉ា ៖ ពូមានគិតថាអនាគតទៅថ្ងៃហ្នឹងវិកិលមកយកដីយើងទេ?

លន់ ៖ មានគិតដែរ ព្រោះកាលពីសម័យសង្គ្រាមខ្ញុំធ្លាប់រស់នៅមុំ ០៣ រហូតមកដល់៨០៨នេះខ្ញុំរស់នៅជាយដែននេះ មិនមែននៅនេះទេ គឺនៅក្នុងទៀត!

ដារ៉ា ៖ នៅក្នុងទៀតពូគិតវាជាទឹកដីយើង ឬក៏យ៉ាងម៉េច?

លន់ ៖ ខ្ញុំមិនបានកាន់ដែនទីដាក់លាក់ទេ!

ដារ៉ា ៖ តាមពូធ្វើម៉េចដើម្បីទប់ស្កាត់ពីបញ្ហាហ្នឹង?

លន់ ៖ តាមខ្ញុំៗសង្ឃឹមទៅខាងលើដូចតែគ្នា ក្នុងការដោះស្រាយបញ្ហារឿងព្រំដែនហ្នឹង!

ដារ៉ា ៖ ពូមានអីចង់បន្ថែមទេ?

លន់ ៖ ខ្ញុំចង់បានការអភិវឌ្ឍឲ្យមកដល់ស្រុកភូមិខ្ញុំ ហើយអីដែលខ្ញុំចង់បានធំបំផុតគឺ ចង់ឲ្យកម្ពុជាមានការឯកភាពគ្នា ។

ដារ៉ា ៖ ពូមានដែលនិយាយពីប្រវត្តិរបស់ពូប្រាប់កូនចៅទេ?

លន់ ៖ ប្រាប់!

ដារ៉ា ៖ ភាគច្រើនពូនិយាយពីរឿងអី?

លន់ ៖ ទាក់ទងនឹងការលំបាកដែលគេឲ្យយើងហូប ហើយធ្វើការស្ទើរតែ២៤ម៉ោង ហើយទម្រាំបានក្រោយសមាហរណកម្មនេះវាលំបាកណាស់!

ដារ៉ា ៖ ពូគិតថាគួរតែមានការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យហ្នឹង ទៅដល់សិស្សជំនាន់ក្រោយទេ?

លន់ ៖ ខ្ញុំគាំទ្រឲ្យមានការបង្រៀនរឹតតែប្រសើរ ព្រោះវាជាមេរៀនប្រវត្តិសាស្ត្រ!

ដារ៉ា ៖ ការរៀនបែបហ្នឹងពូគិតថាវាមានប្រយោជន៍ទេ?

លន់ ៖ កុំឲ្យកអ្នកក្រោយនេះដើរទៅផ្លូវនោះ!

ដារ៉ា ៖ ពូគិតថាការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះ ធ្វើឲ្យមានការប៉ះពាលដល់ការផ្សះផ្សាជាតិ និងការធ្វើសមាហណកម្មទេ?

លន់ ៖ ខ្ញុំក៏ជាខ្មែរក្រហមដែរ វាឈឺដែរឈ្មោះថាខ្មែរក្រហម ចុះខ្ញុំមិនមែនអ្នកដឹកនាំទេខ្ញុំក៏ជាយុទ្ធជនដូចតែគេដែរហ្នឹង ហើយអ៊ីដែលខ្ញុំទទួលស្គាល់ការពិតគឺថា ការបង្រួបបង្រួម និងការរស់នៅជាមួយគ្នាបាន ការដែលយើងមានសន្តិភាពក្រោយសមាហរណកម្ម ការដែលយើងមានសេរីភាព ។

ដារ៉ា ៖ អញ្ចឹងការបង្រៀននេះមិនមានការប៉ះពាល់ទេអី?

លន់ ៖ មិនមានការប៉ះពាល់អីទេ សម្រាប់ឲ្យអ្នកក្រោយៗនេះមានការឈឺចាប់ ព្រោះយើងជាអ្នកជួបប្រទះ ។